ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៤០ ស.ស.រ

## សេចក្តីសំរេច

### ស្តីពី

### ការបង្កើតក្រុមការងារថ្នាក់ជាតិដើម្បីអនុវត្តន៍អនុស្សរណៈ នៃការយោគយល់គ្នារវាងរាជរដ្ឋាភិបាលនៃ ព្រះរាជាណាចក្រកម្ពុជា និង រាជរដ្ឋាភិបាលនៃ ព្រះរាជាណាចក្រថៃ ស្តីពី កិច្ចសហប្រតិបត្តិការទ្វេភាគី ដើម្បីលុបបំបាត់ការជួញដូរកុមារ និងស្ត្រី និងជួយដល់ជនរងគ្រោះដោយសារការជួញដូរ

### រាជរដ្ឋាភិបាលកម្ពុជា

-បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញ ព្រះរាជក្រម លេខ ០២/នស/៩៤/៧២ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើ ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញ ព្រះរាជក្រម លេខ នស/រកម/០៦៩៩/០៦ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

-បានឃើញ អនុក្រឹត្យលេខ ៨៧ អនក្រ.បក ចុះថ្ងៃទី ០៤ ខែ តុលា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

-បានឃើញអនុក្រឹត្យលេខ ១៤ អនក្រ.បក ចុះថ្ងៃទី១១ខែមិនាឆ្នាំ២០០៣ ស្តីពីការកែសំរួលរចនាសម្ព័ន្ធរបស់អគ្គនាយកដ្ឋានសង្គមកិច្ច និងយុវនីតិសម្បទា

-យោងសារាចរណែនាំរបស់រាជរដ្ឋាភិបាលលេខ ១៣ សរណន ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ១៩៩៩ ស្តីពីការពង្រឹង និង ពង្រីកចលនាការងារ ប្រឆាំងនឹងការជួញដូរស្ត្រី និងកុមារ

-យោងសេចក្តីប្រកាស លេខ ០១ សប្រក ចុះថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ២០០០ ស្តីពីវិធានការណ៍ចាត់តាំងការអនុវត្តន៍ផែនការជាតិ ០៥ ឆ្នាំ ប្រឆាំងការជួញដូរ និងកេងប្រវ័ញ្ចផ្លូវភេទលើកុមារ

-យោងអនុស្សរណៈការយោគយល់គ្នារវាងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា និង រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រថៃឡង់ដ៍ ស្តីពីកិច្ចសហប្រតិបត្តិការទ្វេភាគី ដើម្បីលុបបំបាត់ការជួញដូរកុមារនិងស្ត្រី និង ជួយ ដល់ជនរងគ្រោះ ដោយសារការជួញដូរ ដែលបានចុះហត្ថលេខាកាលពីថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០០៣ នៅខេត្តសៀមរាប នៃព្រះរាជាណាចក្រកម្ពុជា

-ពិនិត្យសំនូមពរការងារចាំបាច់ សំរាប់កិច្ចសហប្រតិបត្តិការដើម្បីលុបបំបាត់ការជួញដូរមនុស្ស និង ជួយដល់ជនរងគ្រោះ នៃប្រទេសទាំងពីរ កម្ពុជា-ថៃឡង់ដ៍

## សំរេច

**ប្រការ១** : បង្កើតក្រុមការងារថ្នាក់ជាតិដើម្បីអនុវត្តន៍អនុស្សរណៈនៃការយោគយល់គ្នារវាងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា និង រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រថៃឡង់ដ៍ ស្តីពីកិច្ចសហប្រតិបត្តិការទ្វេភាគី ដើម្បីលុបបំបាត់ការជួញដូរកុមារនិងស្ត្រី និងជួយដល់ជនរងគ្រោះដោយសារការជួញដូរ ដែលបានចុះហត្ថលេខា កាលពីថ្ងៃទី៣១ ខែ ឧសភា ឆ្នាំ ២០០៣ នៅខេត្តសៀមរាប នៃព្រះរាជាណាចក្រកម្ពុជា។

**ប្រការ២** : ក្រុមការងារថ្នាក់ជាតិ (National Task force) នេះមានសមាសភាពដូចតទៅ :

| | |
|---|---|
| ១-រដ្ឋលេខាធិការ ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា | ប្រធាន |
| ២-រដ្ឋលេខាធិការ ក្រសួងកិច្ចការនារី និងអតីតយុទ្ធជន | អនុប្រធាន |
| ៣-រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ | អនុប្រធាន |
| ៤-អនុរដ្ឋលេខាធិការ ក្រសួងយុត្តិធម៌ | សមាជិក |
| ៥-អនុរដ្ឋលេខាធិការ ក្រសួងទេសចរណ៍ | សមាជិក |
| ៦-អនុរដ្ឋលេខាធិការ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | សមាជិក |
| ៧-អនុរដ្ឋលេខាធិការ ក្រសួងអប់រំ យុវជន និងកីឡា | សមាជិក |
| ៨-អនុរដ្ឋលេខាធិការក្រសួងពត៌មាន | សមាជិក |
| ៩-ប្រធានក្រុមការងារសំរបសំរួលដំណើរការមាតុភូមិនិវត្តន៍កុមារនិងស្ត្រីដែលត្រូវបានគេជួញដូរឆ្លងកាត់ព្រំដែន កម្ពុជា -ថៃ តាមប្រកាសលេខ៤៧០ប្រក/សកបយ ចុះថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០០៣ | សមាជិក |

**ប្រការ៣** : ក្រុមការងារថ្នាក់ជាតិនេះមានភារកិច្ចដូចខាងក្រោម :

-រៀបចំរបាយការណ៍ វិភាគអំពីការជួញដូរមនុស្សក្នុងប្រទេស និងសហការជាមួយក្រុមការងារប្រទេសថៃ ដើម្បី រៀបចំផែនការសកម្មភាពរួម សំរាប់អនុវត្តន៍អនុស្សរណៈ នៃការយោគយល់គ្នានេះ

-ពិនិត្យតាមដាន និងវាយតំលៃការអនុវត្តនៃអនុស្សរណៈនេះ និងធ្វើរបាយការណ៍ជូនគណៈកម្មការរួម សំរាប់ កិច្ចសហប្រតិបត្តិការទ្វេភាគី កម្ពុជា-ថៃ ក្នុងកិច្ចប្រជុំប្រចាំឆ្នាំរបស់ខ្លួន

-ផ្តួចផ្តើមការបង្កើតយុទ្ធសាស្ត្រ គោលការណ៍សំរាប់អនុវត្ត និងក្របខណ្ឌចាំបាច់ផ្សេងៗទៀត ដើម្បីអនុវត្តន៍ អនុស្សរណៈនេះ

-លើកអនុសាសន៍សំដៅធ្វើអោយមានការរីកចំរើន ក្នុងកិច្ចសហប្រតិបត្តិការទៅវិញទៅមករវាងប្រទេសទាំងពីរ ក្នុង ការប្រយុទ្ធប្រឆាំង នឹងការជួញដូរមនុស្សជាពិសេសកុមារ និងស្ត្រី

-ពិនិត្យឡើងវិញនូវការអនុវត្ត អនុស្សរណៈនេះរៀងរាល់៥ឆ្នាំម្តង

-លើកគំរោងស្នើថវិកាជាតិ ដែលស្ថិតក្នុងបន្ទុកផែនការចំណាយរបស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាល វិជ្ជាជីវៈ និងយុវនីតិសម្បទា និង ពីអង្គការអន្តរជាតិនានា ដូចជា : UNICEF, IOM,...ដើម្បីបំរើសកម្មភាព ការងាររបស់ក្រុមការងារនេះ ។

**ប្រការ៤**: សមាជិកក្រុមការងារថ្នាក់ជាតិនេះ ត្រូវចូលរួមប្រជុំ តាមការអញ្ជើញរបស់ប្រធាន ។

**ប្រការ៥**:ក្រុមការងារថ្នាក់ជាតិនេះ អាចបង្កើតក្រុមការងារថ្នាក់ខេត្ត/ក្រុង ដើម្បីពិនិត្យតាមដានអំពើជួញដូរមនុស្ស និង សំរបសំរួលដំណើរការមាតុភូមិនិវត្តន៍កុមារ និងស្ត្រី ដែលត្រូវបានគេជួញដូរឆ្លងដែន ។

**ប្រការ៦**: ក្រុមការងារអន្តរក្រសួងនេះ ត្រូវប្រើប្រាស់ក្រុមសំរបសំរួលដំណើរការមាតុភូមិនិវត្តន៍កុមារ និងស្ត្រី ដែលត្រូវ បានគេជួញដូរឆ្លងកាត់ព្រំដែនកម្ពុជា-ថៃ តាមប្រកាសលេខ ៤៧០ ប្រក/សកបយ ចុះថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០០៣ **ជាលេខាធិការដ្ឋានអចិន្ត្រៃយ៍** ។ លេខាធិការដ្ឋានអចិន្ត្រៃយ៍របស់ក្រុមការងារថ្នាក់ជាតិនេះ មានទី ស្នាក់ការមួយនៅ អគ្គនាយកដ្ឋានសង្គមកិច្ច និងយុវនីតិសម្បទា នៃក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាល វិជ្ជាជីវៈ និងយុវនីតិសម្បទា។ ក្រុមការងារថ្នាក់ជាតិនេះ មានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងសង្គមកិច្ច ការ ងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ដើម្បីដំណើរការការងារ ។

**ប្រការ៧** : បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយពីសេចក្តីសំរេចនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ៨** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវ នីតិសម្បទា រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រី

ក្រសួងកិច្ចការនារី និងអតីតយុទ្ធជន រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ រដ្ឋមន្ត្រីក្រសួងទេសចរណ៍ រដ្ឋមន្ត្រីក្រសួងពត៌មាន រដ្ឋមន្ត្រីក្រសួងអប់រំ យុវជននិងកីឡា និង រដ្ឋមន្ត្រី រដ្ឋលេខាធិការក្រសួងពាក់ព័ន្ធ និងបណ្តាសមាសភាពដូចមានចែងក្នុងប្រការ២ មានភារកិច្ចអនុវត្តន៍សេចក្តីសំរេចនេះអោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
-ដូចមាត្រា ៨ ដើម្បីអនុវត្តន៍
-ឯកសារ-កាលប្បវត្តិ